# [05]

# Rebirth

## *Where do beings come from and where are they going?*

There are three possible answers to this question. Those who believe in a god or gods usually claim that before an individual is created, he/she does not exist, then he/she comes into being through the will of a god. He/she lives their life and then, according to what they believe or do in their life, they either go to eternal heaven or hell. There are others, humanists and scientists, who claim that the individual comes into being at conception due to natural causes, lives and then at death, ceases to exist. Buddhism does not accept either of these explanations. The first gives rise to many ethical problems If a good god really creates each of us, it is difficult to explain why so many people are born with the most dreadful deformities, or why so many children are miscarried just before birth or are still-born. Another problem with the theistic explanation is that it seems very unjust that a person should suffer eternal pain in hell for 60 or 70 years of non-belief or immoral living. Likewise, 60 or 70 years of good living seems a very small outlay for eternal bliss in heaven. for what he/she did in those years on Earth.

# ភាគ ៥

# ការកើតថ្មី

## *តើពួកសត្វលោកទាំងអស់កើតមកពីណា ហើយពេលពួកគេស្លាប់ទៅកើតទីណា?*

មានចំឡើយពីរដែលអាចឆ្លើយបានចំពោះសំនួរនេះ។ អ្នកទាំងនោះដែលជឿលើឯកាទិទេពឬពហុអាទិទេពជាធម្មតាអះអាងថាមុនពេលកើតមានបុគ្គលម្នាក់ប្រុសឬស្រីមិនទាន់មានដូចសព្វថ្ងៃទេបន្ទាប់ពីខ្លួនគាត់ឬក៏ខ្លួននាងមានជីវិតឡើងបានដោយសារបំណងព្រះអាទិទេព។ ខ្លួនគាត់ឬខ្លួននាងរស់រានមានជីវិតមកទាល់ពេលនេះ អាស្រ័យធ្វើតាមនូវអ្វីដែលគេជឿហើយបដិបត្តិសំរាប់ជីវិតរបស់គេ ពួកគេក៏កើតផងដែរក្នុងឋានសួគ៌ាឬឋាននរក។ មានអ្នកផ្សេងៗទៀតដូចជាអ្នកមនុស្សវិទ្យា អ្នកវិទ្យាសាស្ត្រ ដែលអះអាងថាបុគ្គលម្នាក់ៗកើតមានជីវិតអាស្រ័យទៅលើសាហេតុធម្មជាតិ មានជីវិតហើយបន្ទាប់មកក៏ស្លាប់ មិនមានអ្វីសេសសល់ទៀត ព្រះពុទ្ធសាសនាមិនទទួលស្គាល់ផងដែរនូវការពន្យល់ទាំងនេះ។ បញ្ហាទី១បង្កើតជាបញ្ហាចរិយធម៌ច្រើន។ បើអាទិទេពល្អៗពិតជាបានបង្កើតពួកយើងម្នាក់ៗ វាពិបាកនឹងពន្យល់ថាហេតុអ្វីបានជាមនុស្សភាគច្រើនវិកលវិការគួរអោយខ្លាច ឬហេតុអ្វីក្មេងចំនួនជាច្រើនខុសគេតាំងពីកំណើត ហើយនៅតែមានដូច្នេះ។ បញ្ហាមួយទៀតជាមួយនឹងការពន្យល់ដោយពួកជឿលើអាទិទេព គឺថាវាហាក់បីដូចជាអយុត្តិធម៌ដែលមនុស្សទទួលរងទុក្ខវេទនាក្នុងខ្លួនក្នុងឋាននរកអស់ពេល៦០,៧០ឆ្នាំពីព្រោះតែការមិនជឿឬអសីលធម៌។ ដូចគ្នាដែរ អ្នករស់នៅប្រកបដោយសីលធម៌៦០,៧០ឆ្នាំ ហាក់ដូចជាទទួលសិទ្ធិទៅកើតទៅសោយសុខនៅឋានសួគ៌ាបានតិចតួចណាស់ សំរាប់បុគ្គលប្រុសស្រីនោះបានធ្វើក្នុងកំឡុងរស់នៅក្នុងឋានមនុស្ស។

The second explanation is better than the first and has more scientific evidence to support it but still leaves several important questions unanswered. How can a phenomenon so amazingly complex as consciousness develop from the simple meeting of two cells, the sperm and the egg? And now that parapsychology is a recognised branch of science, phenomena like telepathy are increasingly difficult to fit into the materialistic model of the mind.

### *How does the mind go from one body to another?*

Think of it being like radio waves. The radio waves, which are not made up of words and music but energy at different frequencies, are transmitted, travel through space, and attracted to and picked up by the receiver from where they are broadcast as words and music. It is the same with the mind. At death, mental energy travels through space, is attracted to and picked up by the fertilised egg. As the embryo grows, it centres itself in the brain from where it later broadcasts itself as the new personality.

### *Is one always reborn as a human being?*

No, there are several realms in which one can be reborn. Some people are reborn in heaven, some are reborn in hell, some are reborn as hungry ghosts and so on. Heaven is not a place but a state of existence where one has a subtle body and where the mind experiences mainly pleasure. Some religions strive very hard to be reborn in a heavenly existence mistakenly believing it to

ការពន្យល់ទីពីរគឺអាចល្អជាងទីមួយនិងមានភស្តុតាងជាវិទ្យាសាស្ត្រជាងមុនដើម្បីគាំទ្រ តែនៅសល់សំនួរសំខាន់ៗជាច្រើនដែលនៅមិនទាន់ឆ្លើយ។ តើអព្ភូតហេតុដែលស្មុគស្មាញយ៉ាងខ្លាំងដូចជាវិញ្ញាណអាចវិវត្តន៍ពីការជួបកោសិការពីរម៉ែសាមញ្ញ ទឹកកាមហើយនឹងពងញាស់។ហើយឥឡូវនេះការសិក្សាខាងចិត្តវិស័យជាសាខាដែលទទួលស្គាល់ដោយវិទ្យាសាស្ត្រ អព្ភូតហេតុនៃទូរវេទន៍គឺលំបាកខ្លាំងឡើងដើម្បីតំរូវទៅនឹងរូបបែបខាងវត្ថុវិស័យនៃសភាវះចិត្ត។

### *តើចិត្តចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានយ៉ាងណា?*

គិតអំពីអ្វីមួយប្រដូចទៅនឹងរលកវិទ្យុ។ រលកវិទ្យុដែលមិនកើតឡើងពីពាក្យសំដីឬតន្ត្រីតែជាកំឡាំងក្នុងរលកប្រដេញចង្វាក់ខុសគ្នា ដែលជំរុញតពីមួយទៅមួយ ហោះហើរឆ្លងកាត់ស្រទាប់បរិយាកាស ហើយដាច់ចេញ និងជ្រៀតចូលដោយគ្រឿងទទួលពីកន្លែងដែលជាកន្លែងផ្សាយចេញជាពាក្យពេចនិងតូរតន្ត្រី។ វាក៏ដូចគ្នាដែរជាមួយនឹងចិត្ត។ ពេលស្លាប់ទៅកំឡាំងចិត្តហោះហើរឆ្លងកាត់ស្រទាប់បរិយាកាស គឺរសាត់ចេញនិងរសាត់ចូលដោយពងញាស់ដែលល្អ។ ទារកក្នុងស្បូនធំធាត់ឡើង វាតំកល់ខ្លួនឯងចំកណ្តាលជាខួរក្បាលជាកន្លែងដែលក្រោយមកផ្សាយចេញខ្លួនឯងក្លាយជាខ្លួនមនុស្សថ្មីឡើង។

### *តើមនុស្សម្នាក់ៗសុទ្ធតែកើតកំណើតជាមនុស្សទាំងអស់គ្នាឬ?*

ទេ, មានភពច្រើនណាស់ដែលម្នាក់ៗអាចចាប់កំណើតឡើងវិញ។ មនុស្សខ្លះកើតក្នុងឋានសួគ៌ា អ្នកខ្លះកើតក្នុងឋាននរក អ្នកខ្លះកើតជាប្រេតនិងផ្សេងៗទៀត។ ឋានសួគ៌ាមិនមែនជាទីកន្លែងទេ តែជាអង្គប្រជុំសភាវះដែលម្នាក់ៗមានរូបកាយល្អិតនិងជាកន្លែងដែលចិត្តសោយសុខដ៏សំខាន់។សាសនាខ្លះព្យាយាមយ៉ាងខ្លាំងដើម្បីកើតក្នុងភពសួគ៌ាដែលជឿយ៉ាងខុសៗថាជាប្រជុំជីវិតអចិន្ត្រៃយ៍។

be a permanent state. But it is not. Like all conditioned states, heaven is impermanent and when one's life span there is finished, one could well be reborn again as a human. Hell, likewise, is not a place but a state of existence where one has a subtle body and where the mind experiences mainly anxiety and distress. Being a hungry ghost, again, is a state of existence where the body is subtle and where the mind is continually plagued by longing and dissatisfaction.

So heavenly beings experience mainly pleasure, hell beings and ghosts experience mainly pain and human beings experience usually a mixture of both. So the main difference between the human realm and other realms is the body type and the quality of experience.

Buddhism offers the most satisfactory explanation of where beings come from and where they are going. When we die, the mind, with all the tendencies, preferences, abilities and characteristics that have been developed and conditioned in this life, re-establishes itself in a fertilised egg. Thus the individual grows, is re-born and develops a personality conditioned both by the mental characteristics that have been carried over. And by the new environment, the personality will change and be modified by conscious effort ;and conditioning factors like education, parental influence and society and once again at death, re-establishing itself in a new fertilised egg. This process of dying and being reborn will continue until the conditions that cause it, craving and ignorance, cease.

តែវាមិនដូច្នោះទេ។ ដូចគ្នានឹងលក្ខណ្ឌភពដទៃឋានសួគ៌ាគឺជាអនិច្ចំហើយពេលជីវិតមនុស្សម្នាក់នៅឋាននេះបានបញ្ចប់ អ្នកនោះអាចកើតឡើងវិញម្តងទៀតជាមនុស្ស។ ដូចគ្នាដែរនរកក៏មិនមែនជាទីកន្លែង តែជាឋានមានពិតមួយដែលមនុស្សមានរូបកាយល្អិត ហើយជាឋានដែលចិត្តជួបប្រទះតែភាពអន្ទះសារនិងសេចក្តីទុក្ខភ័យ។ ដូចគ្នា កើតជាប្រេតអត់ឃ្លានឋានពិតមួយដែលមានខ្លួនល្អិតហើយជាកន្លែងដែលចិត្តទ្រាំទុក្ខយូរអង្វែងដោយការញាំញីនៃការស្រេកឃ្លានមិនចេះចប់។

ដូច្នេះសត្វកើតក្នុងសួគ៌ាសោយសុខ កើតជាសត្វនរកឬប្រេតសោយនូវទុក្ខ និងកើតជាមនុស្សសោយទុក្ខផងសុខផងផ្សំគ្នារឿយទៅ។ ដូច្នេះភាពខុសគ្នាសំខាន់រវាងឋានមនុស្សនិងឋានផ្សេងទៀតមានចំពោះលក្ខណះរាងកាយនិងការសោយសុខនិងទុក្ខ។

ព្រះពុទ្ធសាសនាផ្តល់អោយការពន្យល់ដ៏គួរអោយពេញចិត្តបំផុតចំពោះមនុស្សកើតមកពីទីណា?ហើយស្លាប់ទៅ ទៅកើតទីណា?។ ពេលយើងស្លាប់ចិត្តវិញ្ញាណព្រមជាមួយចុតិចិត្តវិបាកកម្ម បុណ្យកុសល និងលក្ខណះវិស័យដែលបានអភិវឌ្ឍន៏និងកំណត់លក្ខណ្ឌជីវិត កសាងខ្លួនឯងឡើងវិញក្នុងកំណើតស៊ុតដែលមានលក្ខណះគ្រប់បរិបូរ។ ដូច្នេះ ការធំលូតលាស់របស់មនុស្សម្នាក់ៗ គឺកើតរលត់ហើយអភិវឌ្ឍន៏លក្ខណ្ឌខ្លួនឯងព្រមទាំងលក្ខណះផ្លូវចិត្តដែលត្រូវបានវិវត្តន៏បន្តរហូត។ ហើយអាស្រ័យបរិដ្ឋានថ្មី រូបកាយម្នាក់ៗនឹងផ្លាស់ប្តូរដោយកំណត់ទៅតាមការព្យាយាមរបស់វិញ្ញាណ និងកំណត់កត្តាសំខាន់ទាំងឡាយដូចជាការសិក្សា តំណរពូជពីឱពុកម្តាយ និងសង្គមហើយស្លាប់ម្តងទៀត រួចទៅចាប់កំណើតនៅក្នុងស៊ុតដែលមានលក្ខណះគ្រប់បរិបូរ។ ការវិលវល់ស្លាប់និងកើតនេះនឹងបន្តរហូតលក្ខណ្ឌដែលបណ្តាលអោយស្លាប់និងកើត គឺតណ្ហានិងអវិជ្ជាត្រូវបានបញ្ចប់។

When they do, instead of being reborn, the mind attains a state called Nirvana and this is the ultimate goal of Buddhism and the purpose of life.

## *What decides where we will be reborn?*

The most important factor, but not the only one, influencing where we will be reborn and what sort of life we shall have, is karma. The word karma means action and refers to our intentional mental actions. In other words, what we are is determined very much by how we have thought and acted in the past. Likewise, how we think and act now will influence how we will be in the future.

The gentle, loving type of person tends to be reborn in a heaven realm or as a human being who has a predominance of pleasant experiences. The anxious, worried or extremely cruel type of person tends to be reborn in a hell realm or as a human being who has a predominance of painful experiences. The person who develops obsessive craving, fierce longings, and burning ambitions that can never be satisfied tends to be reborn as a hungry ghost or as a human being frustrated by longing and wanting. Whatever mental habits are strongly developed in this life will continue in the next life. Most people, however, are reborn as human beings.

## *So if our lives are determined by our karma, can we change it?*

ពេលពួកគេបដិបត្តិរហូតដល់មិនកើតមកវិញម្តងទៀតព្រោះចិត្តសំរេចបាននូវធម៌ជាន់ខ្ពស់ហៅថាព្រះនិព្វាន ហើយជាទិសដៅខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនា និងជាគោលបំណងរបស់ជីវិត។

## *តើអ្វីដែលកំណត់នូវទីកន្លែងដែលយើងទៅកើត?*

កត្តាសំខាន់បំផុត តែមិនមែនមានតែមួយទេ ដែលជះឥទ្ធិផលអោយយើងកើតម្តងទៀតហើយជីវិតប្រភេទណាដែលយើងត្រូវកើតគឺអាស្រ័យទៅលើកម្មរបស់យើង។ ពាក្យថាកម្មមានន័យថាអំពើហើយសំដៅទៅលើចេតនាកម្មរបស់យើង។ ន័យផ្សេងទៀតសំដៅទៅលើការកំណត់អំពើទាំងឡាយដែលយើងបានគិតនិងបានប្រព្រឹត្តក្នុងអតីតកាលកន្លងមក។ ដូចគ្នាដែរអ្វីដែលយើងគិតនិងប្រព្រឹត្តក្នុងបច្ចុប្បន្ននេះនឹងមានឥទ្ធិពលក្នុងកំណើតនាពេលអនាគតខាងមុខទៀត។

មនុស្សដែលមានមេត្តាករុណានិងភាពសុច្ចរិតទៀងត្រង់នឹងទៅកើតក្នុងឋានសួគ៌ាឬមកកើតជាមនុស្សដែលបរិបូរទៅដោយភោគសម្បត្តិនិងសេចក្តីសុខ។ មនុស្សដែលកាចឃោរឃៅ ធ្វើអំពើបាបឬទុក្ខក្រវល់ក្រវាយនឹងទៅកើតក្នុងឋាននរកឬកើតជាមនុស្សដែលពោរពេញទៅដោយសេចក្តីទុក្ខចុកចាប់។ មនុស្សដែលបង្កើនចំណង់តណ្ហាមិនចេះចប់ បង្កើនចំណង់តណ្ហាខ្លាំងឡើយៗបន្តទៀត និងមហិច្ឆតាដែលពុះកញ្ជ្រោលខ្លាំង មិនចេះស្កប់ស្កល់ធ្វើអោយកើតម្តងហើយម្តងទៀតដូចជាប្រេតឬមនុស្សលោកជួបនូវសេចក្តីទុក្ខដោយការវិលវល់យូរអង្វែងនឹងចំណង់តណ្ហា។ យ៉ាងណាក៏ដោយកំលាំងផ្លូវចិត្តគឺទ្រទ្រង់យ៉ាងពិតប្រាកដនូវជីវិតជាតិនេះហើយនឹងបន្តទៀតរហូតដល់ជាតិខាងមុខ។ទោះបីយ៉ាងណា មនុស្សភាគច្រើនកើតជាមនុស្សម្តងទៀត។

## *ដូច្នេះបើជីវិតរបស់យើងត្រូវកំណត់ដោយកម្មរបស់យើង តើអាចដូរវាបានទេ?*

Of course we can. That is why one of the steps on the Eightfold Path is Right Effort. It depends on our sincerity, how much energy we exert and how strong the habit is. But it is true that some people singly go through life under the influence of their past habits, without making an effort to change them and falling victim to these unpleasant results. Such people will continue to suffer unless they change their negative habits. The longer the negative habits remain, the more difficult they are to change. The Buddhist understands this and takes advantage of each and every opportunity to break mental habits that have unpleasant results and to develop mental habits that have pleasant and happy results. Meditation is one of the techniques used to modify the habit patterns of the mind as does speaking or refraining to speak in certain ways, and acting or refraining to act in certain ways. The whole of the Buddhist life is a training to purify and free the mind. For example, if being patient and kind was a pronounced part of your character in your last life, such tendencies will re-emerge in the present life. If they are strengthened and developed in the present life, they will re-emerge even stronger and more pronounced in the future life. This is based upon the simple and observable fact that long established habits tend to be difficult to break.

Now, when you are patient and kind, it tends to happen that you are not so easily ruffled by others, you

តាមពិតយើអាចប្តូរបាន។ នោះគឺសាហេតុដែលជាជំហានមួយក្នុងចំណោមជំហានទាំងប្រាំបីឬអរិយមគ្គប្រកបដោយអង្គ៨គឺសម្មាវាយាម។វាអាស្រ័យលើការជឿជាក់របស់យើងប្រើកំលាំងព្យាយាមច្រើនយ៉ាងណានិងការតស៊ូក្រាញនឿលយ៉ាងណា។ តែវាជាសេចក្តីពិតដែលមនុស្សខ្លះពឹងផ្អែកទៅលើបុណ្យដែលគេមានពីអតីតកាលតែម្យ៉ាង ដោយមិនព្យាយាមក្រាញនឿលផ្លាស់ប្តូរវាព្រមទាំងធ្លាក់ខ្លួនជាជនរងគ្រោះនូវវិបាកកម្មដ៏អាក្រក់នេះ។ មនុស្សបែបនោះនឹងទទួលរងទុក្ខបន្តទៀតបើគេមិនប្តូរទំលាប់អវិជ្ជមានរបស់គេ។ ទំលាប់អាក្រក់កាន់តែមានអាយុយូរអង្វែង សេចក្តីលំបាកនឹងកាន់តែពិបាកនឹងផ្លាស់ប្តូរ។ ពុទ្ធសាសនិកជនយល់ដូច្នេះ ហើយម្នាក់ៗអភិវឌ្ឍន៏ខ្លួនឯងព្រមទាំងគ្រប់ឱកាសទាំងអស់ដើម្បីកាច់បំបាក់សន្តានផ្លូវចិត្តដែលមានវិបាកកម្មជាទុក្ខ និងអភិវឌ្ឍន៏ផ្លូវចិត្តដែលមានវិបាកជាសុខនិងជាមង្គល។ សមាធិគឺជាតិចនិចមួយក្នុងចំណោមតិចនិចទាំងឡាយបដិបត្តិដើម្បីសង្កត់ទំលាប់ដែលជាផ្លូវចិត្តក្នុងខណៈកំពុងនិយាយ ឬវៀរចាកការនិយាយក្នុងរឿងណាមួយតែម្យ៉ាង និងកំពុងប្រព្រឹត្តឬវៀរចាកប្រព្រឹត្តវិធីណាមួយតែម្យ៉ាង។ ក្នុងមួយជីវិតរបស់ពុទ្ធសាសនិកជនគឺជាការព្យាយាមសំអាតនិងជំរះផ្លូវចិត្ត។ ជាឧទាហរណ៏ បើមានការអត់ធន់និងករុណាធម៏គឺជាផ្នែកត្រឹមត្រូវនៃចារឹកលក្ខណៈជីវិតជាតិមុនរបស់អ្នក ដូចជាឧប្បនិស្ស័យនឹងកើតឡើងម្តងទៀតក្នុងជីវិតបច្ចុប្បន្ន។ បើឧប្បនិស្ស័យនេះត្រូវបានពង្រឹងនិងអភិវឌ្ឍន៏ក្នុងជាតិនេះ នឹងមានម្តងទៀតកាន់តែខ្លាំងឡើងនិងសមរម្យថែមទៀតក្នុងជាតិខាងមុខ។ នេះស្ថិតលើកត្តាដែលអាចសង្កេតបាននិងសាមញ្ញបំផុត ដែលបានបង្កើតទំលាប់ពីយូរយារណាស់មកហើយ លំបាកនឹងបំបែកអោយប្តូរបាន

ឥឡូវនេះ ពេលអ្នកមានការអត់ធន់និងករុណាធម៏ វានឹងកើតឡើងចំពោះអ្នក អ្នកដទៃពិបាកនឹងបង្កបញ្ហាដល់អ្នក ហើយអ្នកជាមនុស្សមិនគំរោះគំរើយ

don’t hold grudges, people like you and thus your experiences tends to be happier.

Now, let us take another example. Let us say that you come into life with a tendency to be patient and kind due to your mental habits in the past life. But in the present life, you neglect to strengthen and develop such tendencies. They would gradually weaken and die out and perhaps be completely absent in the future life. Patience and kindness being weak in this case, there is a possibility that in either this life or in the next life, a short temper, anger and cruelty could grow and develop, bringing with them all the unpleasant experiences that such attitudes create. We will take one last example. Let us say that due to your mental habits in the last life, you came into the present life with the tendency to be short-tempered and angry, and you realise that such habits only cause you unpleasantness and so you make an effort to change them. You replace them with positive emotions. If you are able to eliminate them completely, which is possible if you make an effort, you become free from the unpleasantness caused by being short tempered and angry. If you are only able to weaken such tendencies, they would re-emerge in the next life where with a bit more effort, they could be eliminated completely and you could be free from their unpleasant effects.

***You have talked a lot about rebirth but is there any proof that we will be reborn when we die?***

មនុស្សទាំងឡាយនឹងចូលចិត្តអ្នក ហើយជីវិតការរស់នៅរបស់អ្នកកាន់តែសុខឡើងៗ ។

ឥឡូវយើងនឹងពិសោធន៍មើលឧទាហរណ៍មួយទៀត។ យើងគួរនិយាយថាអ្នកកើតមកជាតិនេះជាមួយនឹងឧប្បនិស្ស័យអត់ធន់និងមានករុណាធម៌អាស្រ័យដោយអ្នកមានឧប្បនិស្ស័យខាងផ្លូវចិត្តរបស់អ្នកកាលពីជាតិមុន។ តែនៅជាតិនេះអ្នកលះបង់ការពង្រឹងនិងអភិវឌ្ឍន៍ឧប្បនិស្ស័យទាំងនេះ។ ឧប្បនិស្ស័យទាំងនេះនឹងខ្សោយចុះជាបន្តបន្ទាប់ហើយរលប់រលាយបាត់ទៅព្រមទាំងអាចបាត់បង់ទៅទាំងអស់ក្នុងជាតិខាងមុខ។ខន្តីធម៌និងករុណាធម៌អាចចុះខ្សោយក្នុងករណីនេះ អាចប្រព្រឹត្តទៅបានទាំងជាតិនេះឬជាតិក្រោយ ការឡើងទោសះ សេចក្តីក្រោធនិងចិត្តយង់ឃ្នងអាចលាស់ធំឡើងនិងអភិវឌ្ឍន៍ទៀត ផ្តល់អោយពួកគេនូវជីវិតដែលគ្មានសេចក្តីសុខព្រោះតែឥរិយាបទដែលគេបង្កើតដូចនោះ។ យើងនឹងពិសោធន៍ឧទាហរណ៍ចុងក្រោយថែមមួយទៀត។ យើងគួរនិយាយថាអាស្រ័យដោយឧប្បនិស្ស័យជាតិមុនរបស់អ្នក ពេលអ្នកមកកើតក្នុងជាតិនេះមានឧប្បនិស្ស័យជាមនុស្សមានទោសះចារិកនិងក្រោធខឹង ហើយអ្នកដឹងថាឧប្បនិស្ស័យបែបនេះបណ្តាលអោយអ្នកមានសេចក្តីទុក្ខតែម្យ៉ាង ដូច្នេះអ្នកគួរតែព្យាយាមផ្លាស់ប្តូរវាចេញ។ អ្នកផ្លាស់ប្តូរវាដោយអារម្មណ៍ដែលវិជ្ជមាន។ បើអ្នកអាចកំចាត់វាចេញបានទាំងស្រុង ដែលអាចកំចាត់បានទាល់តែអ្នកព្យាយាម អ្នកនឹងបានជ្រះស្រឡះពីសេចក្តីទុក្ខដែលបណ្តាលមកពីទោសះចារិកនិងសេចក្តីមានះក្រេវក្រោធ។ បើអ្នកអាចបន្ថយឧប្បនិស្ស័យដូច្នេះបានតែបន្តិច វាអាចនឹងមានម្តងទៀតក្នុងជាតិក្រោយជាមួយនឹងសេចក្តីព្យាយាមច្រើនឡើងបន្តិច ហើយវាអាចត្រូវបានកំចាត់ចោលទាំងស្រុង អ្នកនឹងអាចរួចរំដោះពីសេចក្តីទុក្ខទាំងពួង

***អ្នកបានពន្យល់ច្រើនអំពីការកើតម្តងទៀត តែតើមានភស្តុតាងណាមួយទេដែលបញ្ជាក់ថាយើងកើតម្តងទៀតក្រោយពីស្លាប់?***

Not only is there scientific evidence to support Buddhist belief in rebirth, it is the only after-life theory that has any evidence to support it. There is not a scrap of evidence to prove the existence of heaven and of course evidence of annihilation at death must be lacking. But during the last 30 years parapsychologists have been studying reports that some people have vivid memories of their former lives. For example, in England, a 5 year old girl said she could remember her other mother and father and she talked vividly about what sounded like the events in the life of another person. Parapsychologists were called in and asked her hundreds of questions to which she gave answers. She spoke of living in a particular village, in what appeared to be Spain. She gave the name of the village, the name of the street she lived in, her neighbours' names and details about her everyday life there. she also tearfully spoke of how she had been struck by a car and died of her injuries two days later. When these details were checked, they were found to be accurate. There was a village in Spain with the name the child had given. There was a house of the type she had described in the street she had named. What is more, it was found that a 23 year old woman living in the house had been killed in a car accident five years before.

Now how is it possible for a five year old living in England who had never been to Spain to know all these details? And of course, this is not the

មិនមែនមានតែភស្តុតាងខាងវិទ្យាសាស្ត្រទេដែលគាំទ្រដល់ជំនឿការកើតថ្មីរបស់ពុទ្ធសាសនិកជន វាគឺពិតជាទ្រឹស្តីជីវិតក្រោយពីការស្លាប់ដែលមានភស្តុតាងខ្លះគាំទ្រវា។ មិនមានចំណិតភស្តុតាងណាបញ្ជាក់នូវភាពមានពិតនៃឋានសួគ៌ហើយនឹងភស្តុតាងសូន្យសុងក្រោយពេលយើងស្លាប់ដែរ។ ប៉ុន្តែ៣០ឆ្នាំចុងក្រោយនេះអ្នកស្រាវជ្រាវខាងចិត្តវិញ្ញាណកំពុងសិក្សាស្រាវជ្រាវពត៌មានដែលថាមនុស្សខ្លះចាំជាតិកំណើតខ្លួនឯងបាន។ឧទាហរណ៏ ក្នុងប្រទេសអង់គ្លេសក្មេងស្រីអាយុ៥ឆ្នាំបាននិយាយថានាងអាចចងចាំម្តាយនិងឪពុកដទៃទៀតរបស់នាង ហើយនាងនិយាយយ៉ាងជាក់ស្តែងអំពីអ្វីដែលហាក់ដូចជាហេតុការណ៏នៃជីវិតមនុស្សមួយផ្សេងទៀត។ អ្នកសិក្សាស្រាវជ្រាវខាងចិត្តវិញ្ញាណបាននាំនាងចូលមកហើយសួរសំណួរជាច្រើនចំពោះអ្វីដែលនាងបានឆ្លើយ។ នាងនិយាយអំពីការរស់នៅក្នុងភូមិមួយច្បាស់លាស់ ដែលរឿងនោះកើតឡើងក្នុងប្រទេសអេស្បាញ៉ុល។ នាងបានប្រាប់ឈ្មោះភូមិ ឈ្មោះផ្លូវដែលនាងរស់នៅ ឈ្មោះញាតិជិតខាងរបស់នាង និងជីវិតរស់នៅប្រចាំថ្ងៃទីនោះដោយលំអិត។ នាងក៏បាននិយាយទាំងទឹកភ្នែកនូវសាហេតុដែលនាងឡានជល់ហើយរបួសស្លាប់ពីរថ្ងៃក្រោយមក។ នៅពេលភាពលំអិតនេះត្រូវបានត្រួតពិនិត្យយ៉ាងច្បាស់លាស់ ពួកគេឃើញថាអ្វីដែលនាងនិយាយគឺជាសេចក្តីពិត។ មានភូមិនោះនៅក្នុងប្រទេសអេស្បាញ ព្រមទាំងឈ្មោះកូនដែលនាងបានប្រាប់។ មានផ្ទះមួយមានទំរង់ដូចដែលនាងបានអធិប្បាយនៅជាប់លេខផ្លូវដែលនាងបានប្រាប់ឈ្មោះ។ ភស្តុតាងច្រើនជាងនេះទៀតគឺមានស្ត្រីអាយុ២៣ឆ្នាំដែលរស់នៅក្នុងផ្ទះនេះបានត្រូវស្លាប់ដោយឧបទ្ទវហេតុដោយរថយន្តជល់កាលពី៥ឆ្នាំមុន។

ឥឡូវនេះ តើវាអាចពិតបានទេដែលក្មេងស្រីអាយុ៥ឆ្នាំក្នុងប្រទេសអង់គ្លេសដែលមិនដែលបានទៅប្រទេសអេស្បាញសោះដឹងអ្វីគ្រប់យ៉ាងអំពីទីនោះ? ហើយតាមពិតនេះគឺមិនមែន

only case of this type. Professor Ian Stevenson of the University of Virginia's Department of Psychology has described dozens of cases of this type in his books. He is an accredited scientist whose 25 year study of people who remember former lives is very strong evidence for the Buddhist teaching of rebirth.

***You say that talk about devils is superstitious. Isn't talk about rebirth a bit superstitious too?***

The dictionary defines superstition as a belief which is not based on reason or fact but on an association of ideas, as in magic. If you can show me a careful study of the existence of devils written by a scientist I will concede that belief in devils is not superstition. But I have never heard of any research into devils; scientists simply wouldn't bother to study such things, so I say there is no evidence for the existence of devils. But as we have just seen, there is evidence which seems to suggest that rebirth does take place. So if belief in rebirth is based on at least some facts, it cannot be a superstition.

***Well, have there ever been any scientists who believe in rebirth?***

Yes. Thomas Huxley, who was responsible for having science introduced into the 19th century British school system and who was the first scientist to defend

ជាករណីតែមួយចំពោះរឿងនេះទេ។ លោកសាស្ត្រាចារ្យអៀនស្ទេវិនសិននៃសាកលវិទ្យាល័យវើជិនញៀ មហាវិទ្យាល័យចិត្តសាស្ត្របានអធិប្បាយរាប់រយផងអំពីករណីមនុស្សដឹងជាតិនេះនៅក្នុងសៀវភៅរបស់គាត់។ គាត់ជាអ្នកវិទ្យាសាស្ត្រដែលគេទទួលស្គាល់ច្រើនដែលការសិក្សា២៥ឆ្នាំអំពីមនុស្សចាំជាតិរបស់គាត់គឺមានភស្តុតាងដ៏ច្បាស់លាស់សំរាប់ទ្រឹស្តីចាប់កំណើតថ្មីរបស់ព្រះពុទ្ធសាសនា។

***អ្នកនិយាយថា ការនិយាយអំពីបិសាចគឺជាអភិនិហារ។ តើការនិយាយអំពីការកើតម្តងទៀតមិនមែនជារឿងអភិនិហារនោះដែរឬទេ?***

វចនានុក្រមកំណត់និយមន័យអភិនិហារថាជាជំនឿមួយដែលមិនស្ថិតលើហេតុផលឬព្រឹត្តិការណ៏តែមានទំនាក់ទំនងនឹងគំនិត ដូចនៅក្នុងមន្តអាគម។ បើអ្នកអាចបង្ហាញខ្ញុំការសិក្សានូវការមានបិសាចពិតប្រាកដដែលសរសេរដោយអ្នកវិទ្យាសាស្ត្រម្នាក់ ខ្ញុំនឹងទទួលយកជំនឿលើបិសាចថាមិនមែនជាអភិនិហារ។ តែខ្ញុំមិនដែលឮអំពីការសិក្សាស្រាវជ្រាវរឿងបិសាចណាមួយទេ អ្នកវិទ្យាសាស្ត្រដូចជាប្រក្រតីដែលមិនអើពើនឹងការសិក្សារឿងនេះ ដូច្នេះខ្ញុំអាចនិយាយថាគ្មានភស្តុតាងណាបញ្ជាក់ថាមានបិសាចនោះឡើយ។តែដូចដែលយើងទើបតែឃើញមានភស្តុតាងពិតដែលបញ្ជាក់នូវចំងល់រឿងការកើតម្តងទៀតយ៉ាងពិតប្រាកដ។ ដូច្នេះបើជឿលើការកើតថ្មីទៀត យ៉ាងហោចណាស់សំអាងលើព្រឹត្តិការណ៏ជាក់ស្តែងខ្លះ វាមិនមែនជារឿងអភិនិហារឡើយ។

***មែនហើយ តើមានអ្នកវិទ្យាសាស្ត្រណាមួយដែលជឿទៅលើការកើតថ្មីម្តងទៀត?***

បាទមាន។ថូមម៉ាសហាក់ស្លេ ដែលជាអ្នកនាំយករបបគំហើញវិទ្យាសាស្ត្រទៅដាក់ក្នុងប្រព័ន្ធសិក្សាចក្រភពអង់គ្លេសសតវត្សន៏ទី១៩ហើយជាអ្នកវិទ្យាសាស្ត្រទី១ដែលការពារទ្រឹស្តី

Darwin’s theories, believed that reincarnation was a very plausible idea. In his famous book "Evolution and Ethics and other Essays", he says:

"*In the doctrine of transmigration, whatever its origin, Brahmanical and Buddhist speculation found, ready to hand, the means of constructing a plausible vindication of the ways of the Cosmos to man....yet this plea of justification is not less plausible than others; and none but very hasty thinkers will reject it on the ground of inherent absurdity. Like the doctrine of evolution itself, that of transmigration has its roots in the world of reality; and it may claim such support as the great argument from analogy is capable of supplying*".

Then, Professor Gust Stromberg, the famous Swedish astronomer, physicist and friend of Einstein also found the idea of rebirth appealing:

"*Opinions differ whether human souls can be reincarnated on the earth or not. In 1936 a very interesting case was thoroughly investigated and reported by the government authorities in India. A girl (Shanti Devi from Deli) could accurately describe her previous life (at Muttra, five hundred miles from Deli) which ended about a year before her 'second birth'. She gave the name of her husband and child and described her home and life history. The investigating commission brought her to her former relatives,*

របស់ដារិន ដែលជឿថាការអវតារគឺជាគំនិតដែលអាចទទួលយកបាន។ នៅក្នុងសៀវភៅដ៏ល្បីល្បាញរបស់គាត់ “ ការវិវឌ្ឍនាការនិងបញ្ហាចរិយសាស្ត្រនិងអត្ថបទដទៃទៀត” គាត់និយាយថា “ *ក្នុងទ្រឹស្តីការប្តូរពីមួយទៅមួយ ទោះយ៉ាងណាក៏ប្រភពរបស់វា ការកាក់ស្មានរបស់ព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនាត្រូវបានគេរកឃើញ យកមកពិនិត្យរួចហើយឧបករណ៍ការកកើតនោះជាការបញ្ជាក់នូវវិធីការប្តូរពីចក្រវាឡមកមនុស្សដែលអាចយកជាការបាន....សំណើរអោយមានការចង្អុលបញ្ជាក់មានប្រសិទ្ធិភាពមិនតិចជាងទ្រឹស្តីដទៃទៀត និងគ្មាននរណាបដិសេធចោលលើកលែងតែអ្នកគិតដ៏ក្រខ្វក់នឹងបដិសេធវាដោយសារតែភាពមិនទំនងជាប់មកជាមួយ។ ដូចគ្នានឹងទ្រឹស្តីវិវឌ្ឍនាការនោះឯង ដែលការប្តូរតំណែងពីមួយទៅមួយរបស់វាមានឫសគល់របស់វាក្នុងលោកនៃសេចក្តីពិត ហើយវាអាចជាការអះអាងនូវការគាំទ្រដូច្នេះជាមូលដ្ឋានគ្រឹះដ៏អស្ចារ្យពីការផ្ទួរផ្គងគ្នាដែលអាចយកជាការបាន*” ។

ដូចគ្នាដែរ សាស្ត្រាចារ្យហ្គុស ស្ត្រោមប៊ើច ជាអ្នកតារាវិទ្យាដ៏ល្បីល្បាញ ជាអ្នករូបវិទ្យា និងជាមិត្តភក្តិជាមួយលោកអែស្តាញជនជាតិស្វីស បានរកឃើញនូវទ្រឹស្តីការកើតថ្មីដូចដែលអធិប្បាយថា “ *យោបល់គឺខុសគ្នាពីអ្វីដែលវិញ្ញាណមនុស្សអាចអវតារម្តងទៀតនៅលើផែនដីឬទេ។ ក្នុងឆ្នាំ១៩៣៦ ករណីដ៏សំខាន់មួយត្រូវបានគេសិក្សាយ៉ាងលំអិតហើយរាយការណ៍ដោយអាជ្ញាធររដ្ឋាភិបាលឥណ្ឌា។ ក្មេងស្រីម្នាក់ (នាងសន្តិ ទេវី ពីដេលលី) អាចអធិប្បាយដូចឃើញនឹងភ្នែកនូវជីវិតពីអតីតកាលរបស់នាង (នៅឯមុត្រា ចំងាយរាប់រយម៉ៃល៍ពីក្រុងដេលលី) ដែលទើបតែចប់ទៅត្រឹមតែមួយឆ្នាំមុនពេលការកើតជាលើកទីពីររបស់នាង។ នាងបានប្រាប់ស្វាមីនិងកូនរបស់នាងនិងរៀបរាប់ពីផ្ទះព្រមទាំងប្រវត្តិជីវិតរបស់នាង។ ក្រុមអ្នកសិក្សាស៊ើបអង្កេតបាននាំនាងទៅរកញាតិមិត្តដើមរបស់នាង ដែលបានបញ្ជាក់យ៉ាង*

*who verified all her statements. Among the people of India reincarnations are regarded as commonplace; the astonishing thing for them in this case was the great number of facts the girl remembered. This and similar cases can be regarded as additional evidence for the theory of the indestructibility of memory*".

Professor Julian Huxley, the distinguished British scientist who was Director General of UNESCO believed that rebirth was quite in harmony with scientific thinking:

"*There is nothing against a permanently surviving spirit-individuality being in some way given off at death, as a definite wireless message is given off by a sending apparatus working in a particular ways. But it must be remembered that the wireless message only becomes a message again when it comes in contact with a new, material structure - the receiver. So with our possible spirit-emanation. It would never think or feel unless again "embodied" in some way. Our personalities are so based on body that it is really impossible to think of survival which would be in any true sense personal without a body of sorts. I can think of something being given off which could bear the same relation to men and women as a wireless message to the transmitting apparatus for mind*".

Even very practical and down-to-earth people like the American industrialist Henry Ford found the idea of rebirth acceptable.

*ច្បាស់រាល់ការអះអាងរបស់នាង។ ក្នុងចំណោមអ្នកអវតារជនជាតិឥណ្ឌាត្រូវបានគេមើលឃើញថាជាកន្លែងសាមញ្ញធម្មតា វត្ថុដែលគួរអោយភ្ញាក់ផ្អើលសំរាប់ពួកគេក្នុងករណីនេះគឺព្រឹត្តិការណ៍ពិតជាច្រើនដែលក្មេងស្រីនេះបានចងចាំ។ ករណីនេះនឹងស្រដៀងគ្នាដទៃទៀតអាចត្រូវបានគេមើលឃើញថាភស្តុតាងបន្ថែមទៀតសំរាប់ទ្រឹស្តីការចងចាំកំណើតដែលមិនត្រូវបានបំផ្លាញអោយបាត់ទៅនោះ*" ។

សាស្ត្រាចារ្យជូលៀន ហាក់ស្លេ អ្នកវិទ្យាសាស្ត្រជនជាតិអង់គ្លេសដ៏មានកិត្តិនាមដែលជាអគ្គនាយកនៃអង្គការយូណេស្កូជឿថាការកើតថ្មីពិតជាសមស្របទៅនឹងគំនិតខាងវិទ្យាសាស្ត្រ "*គ្មានអ្វីប្រឆាំងនឹងជីវិតខាងចិត្តវិញ្ញាណនៃបច្ចេកបុគ្គលដែលមានជីវិតជាអចិន្ត្រៃយ៍ក្នុងករណីខ្លះបន្ទាប់ពីការស្លាប់ ដូចគ្នានឹងសារដែលគ្មានខ្សែច្បាស់លាស់ ត្រូវបានផ្ញើរចេញដោយការធ្វើការយ៉ាងពិតប្រាកដក្នុងករណីជាក់ច្បាស់មួយ។ តែវាគួរតែចងចាំថាសារឥតខ្សែភ្លើងទាំងនេះ ពិតជាអាចក្លាយជាសារម្តងទៀតពេលវាមកតភ្ជាប់នឹងគ្រឿងទទួលដែលមានគ្រោងសាងជាវត្ថុនិងថ្មី។ដូច្នេះជាមួយនឹងការភាយចេញដែលអាចប្រព្រឹត្តទៅបានរបស់វិញ្ញាណវាមិនដែលគិតឬមានអារម្មណ៍រហូតដល់វាករជារូបរាងម្តងទៀតក្នុងលក្ខណៈខ្លះទៀត។ បុគ្គលិកលក្ខណៈរបស់យើងគឺពឹងផ្អែកទៅលើខ្លួនយើងដែលពិតជាមិនអាចគិតដល់ការមានជីវិតដែលអាចស្ថិតក្នុងលក្ខណៈរូបារម្មណ៍ពិតណាមួយដោយគ្មានប្រភេទនៃខ្លួនប្រាណ។ ខ្ញុំអាចគិតដល់វត្ថុខ្លះដែលត្រូវបានបញ្ជូនចេញដោយអាចទ្រទ្រង់សម្ព័ន្ធភាពដូចគ្នារវាងបុរសនិងស្ត្រីដូចគ្នានឹងសារគ្មានខ្សែភ្លើងបញ្ជូនទៅកាន់វត្ថុបន្លាស់សំរាប់ចិត្តវិញ្ញាណ*" ។

ទោះបីមនុស្សដែលស្ទាត់ជំនាញខ្លាំងនិងចុះមកកាន់ផែនដីដូចជាអ្នកឧស្សាហកម្មហិនរី ហ្វត ជនជាតិអាមេរិកាំង បានរកឃើញគំនិតការទទួលយករឿងការចាប់កំណើតថ្មី

Ford was attracted to the idea of rebirth because, unlike the theistic idea or the materialistic idea, rebirth gives you a second chance to develop yourself. Henry Ford says:

"*I adopted the theory of Reincarnation when I was twenty six. Religion offered nothing to the point. Even work could not give me complete satisfaction. Work is futile if we cannot utilise the experience we collect in one life in the next. When I discovered Reincarnation it was as if I had found a universal plan I realised that there was a chance to work out my ideas. Time was no longer limited. I was no longer a slave to the hands of the clock. Genius is experience. Some seem to think that it is a gift or talent, but it is the fruit of long experience in many lives. Some are older souls than others, and so they know more. The discovery of Reincarnation put my mind at ease. If you preserve a record of this conversation, write it so that it puts men's minds at ease. I would like to communicate to others the calmness that the long view of life gives to us*".

So the Buddhist teachings of rebirth does have some scientific evidence to support it. It is logically consistent and it goes a long way in answering questions what the theistic and the materialistic theories fail to .

ហ្វ៍តបានចាប់អារម្មណ៍ទៅនឹងគំនិតជឿរឿងការកើតថ្មីពីព្រោះការកើតថ្មីផ្តល់ឱកាសជាលើកទី២ ដើម្បីអភិវឌ្ឍន៍ខ្លួនអ្នក ដែលខុសពីគំនិតទេវនិយមឬគំនិតវត្ថុនិយម។ ហិនរី ហ្វ៍តនិយាយថា

“ *ខ្ញុំសំរេចយកទ្រឹស្តីការអវតារពេលខ្ញុំអាយុ២៦ឆ្នាំ។ សាសនាមិនបានផ្តល់អ្វីឡើយចំពោះរឿងនេះ។ ទោះបីការងារមិនបានផ្តល់នូវភាពឆ្អែតឆ្អល់ដល់ខ្ញុំទាំងអស់។ ការងារគឺមានជីជាតិមិនគ្រប់គ្រាន់បើយើងមិនអាចប្រើប្រាស់បទពិសោធន៍ដែលយើងប្រមូលទុកក្នុងជីវិតមួយនាពេលអនាគត។ពេលខ្ញុំរកឃើញការអវតារជីវិតវាហាក់ដូចជាខ្ញុំបានរកឃើញគំរោងចក្រវាឡដែលខ្ញុំជឿច្បាស់ថា មានឱកាសមួយដើម្បីបំពេញគំនិតរបស់ខ្ញុំ។ ពេលវេលានឹងមិនមានកំណត់ព្រំដែនទៀតទេ។ ខ្ញុំនឹងមិនជាទាសករចំពោះទ្រនិចនាឡិការទៀតទេ។ ភាពវាងវៃគឺបទពិសោធន៏។ អ្នកខ្លះគិតថាវាគឺជារង្វាន់ឬទេព្យកោសល្យ តែវាជាផល (វិបាក)នៃបទពិសោធន៏ដ៏យូរអង្វែងក្នុងជាតិជីវិតជាច្រើន។ អ្នកខ្លះគឺមានវិញ្ញាណចាស់ជាងអ្នកដទៃហើយដូច្នេះគេដឹងច្រើនជាង។ ការរកឃើញនូវការអវតារធ្វើអោយចិត្តខ្ញុំស្ងប់។ បើអ្នកទទួលយកការថតការសន្ទនានេះ ចូរសរសេរវា ដូច្នេះអាចធ្វើអោយចិត្តរបស់មនុស្សបានស្ងប់។ ខ្ញុំគប្បីនឹងធ្វើទំនាក់ទំនងជាមួយអ្នកដទៃនូវភាពស្ងប់ស្ងាត់ ដែលទស្សនះរឿងជីវិតដ៏យូរអង្វែងផ្តល់អោយយើង*” ។

ដូច្នេះការប្រៀនប្រដៅរឿងការចាប់កំណើតក្នុងព្រះពុទ្ធសាសនាពិតជាមានភស្តុតាងខាងវិទ្យាសាស្ត្រខ្លះដែលគាំទ្រវា។ វាមានភាវះពិតប្រាកដតាមហេតុបច្ច័យ ហើយវាធ្វើដំណើរនៅលើកំណាត់ផ្លូវវែងឆ្ងាយដើម្បីឆ្លើយនូវសំណួរទាំងឡាយដែលទ្រឹស្តីវត្ថុនិយមនិងទេវនិយមមិនអាចឆ្លើយតបបាន។

It is also very comforting. What can be worse than a theory of life that gives you no second chance, no opportunity to amend the mistakes you have made in this life and no time to further develop the skills and abilities you have nurtured in this life. But according to the Buddha, if you fail to attain Nirvana in this life, you will have the opportunity to try again next time. If you have made mistakes in this life, you will be able to correct yourself in the next life. You will truly be able to learn from your mistakes. Things you were unable to do or achieve in this life may well become possible in the next life. What a wonderful teaching!

វាក៏ជាការសុខស្រួលខ្លាំងណាស់ផងដែរ។ អ្វីដែលអាក្រក់ជាងទ្រឹស្តីជីវិតដែលមិនផ្តល់អោយអ្នកនូវឱកាសទីពីរ គ្មានភ័ព្វសំណាងដើម្បីធ្វើពង្រាងនូវកំហុសឆ្គងដែលអ្នកបានធ្វើក្នុងជាតិនេះ ហើយគ្មានពេលអភិវឌ្ឍន៏បន្ថែមនូវភាពជំនាញនិងលទ្ធភាពដែលអ្នកបានបីបាច់រក្សាក្នុងជីវិតនេះ។ តែតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បើអ្នកមិនបានសំរេចព្រះនិព្វានក្នុងជីវិតនេះទេ អ្នកនឹងមានឱកាសព្យាយាមម្តងទៀតក្នុងជាតិខាងមុខ។ បើអ្នកបានសាងកំហុសឆ្គងក្នុងជាតិនេះ អ្នកនឹងអាចធ្វើអោយត្រឹមត្រូវដោយខ្លួនឯងក្នុងជាតិខាងមុខ។ អ្នកនឹងអាចបានសិក្សាយ៉ាងពិតប្រាកដពីកំហុសឆ្គងរបស់អ្នក។ រឿងរ៉ាវទាំងឡាយដែលអ្នកមិនអាចធ្វើឬសំរេចបានក្នុងជីវិតនេះ អាចនឹងប្រែទៅជាល្អក្នុងជាតិខាងមុខ។ តើពាក្យប្រៀនប្រដៅអ្វីក៏អស្ចារ្យម្លេះ!